

# សៀវភៅមគ្គុទេសក៍ផលិតកម្មពូជស្រូវ

# RICE SEED PRODUCTION MANUAL

គម្រោងបង្កើនផលិតភាពកសិកម្មក្នុងតំបន់ទន្លេសាបប៉ែកខាងលិច

**AGRICULTURAL PRODUCTIVITY PROMOTION PROJECT IN WEST TONLE SAP (APPP)**

© ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន ឆ្នាំ២០១៤ /
2014 Japan International Cooperation Agency

ប្រព័ន្ធផលិតកម្មពូជនៅក្នុងសៀវភៅនេះគឺផ្អែកលើ ″បច្ចេកទេសផលិតកម្មពូជដែលបានណែនាំដោយ គម្រោងAPPP″ ដែលចងក្រងដោយ លោក **យ៉ូស៊ីតូស៊ី ស៊ុស៊ុយ** អតីតជំនាញការផ្នែកខាងគ្រប់គ្រងកសិដ្ឋាននៃទីភ្នាក់ងារJICA។

# អារម្ភកថា



**សៀវភៅមគ្គុទេសក៍ផលិតកម្មពូជស្រូវ**ត្រូវបានរៀបរៀងឡើងដោយគម្រោងបង្កើនផលិតភាព កសិកម្មក្នុងតំបន់ទន្លេសាបប៉ែកខាងលិច(APPP)សហការអនុវត្តន៍ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(MAFF)នៃប្រទេសកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA)។ សៀវភៅនេះគឺគ្រាន់តែជាការបង្ហាត់បង្ហាញ និងណែនាំចំពោះផលិតកម្មពូជស្រូវប៉ុណ្ណោះ និងផ្តល់នូវអំណះអំណានច្បាស់លាស់សំរាប់មន្រ្តីផ្សព្វផ្សាយកសិកម្ម និងប្រជាកសិករ។

ក្នុងនោះសៀវភៅនេះផងដែរត្រូវបានអភិវឌ្ឍន៍ឡើងដោយផ្អែកលើ″ ស្តង់ដារពូជជាតិ″ នៃMAFF កម្ពុជា បន្ថែមដោយបទពិសោធន៍នៃការអនុវត្តន៍ជាក់ស្តែងរបស់គម្រោងAPPPជាមួយនិងការពិចារណាយ៉ាងល្អិតល្អន់នូវស្ថានភាពក្សេត្រសេដ្ឋកិច្ចនៅតាមថ្នាក់មូលដ្ឋាន។

ការធ្វើឲ្យប្រសើរឡើងនូវសន្តិសុខស្បៀងគឺជាការងារអទិភាពរបស់រដ្ឋាភិបាលកម្ពុជា ហើយស្រូវគឺជាដំណាំដ៏មានសារៈសំខាន់ទាក់ទងនិងប្រភពថាមពលរបស់ប្រជាពលរដ្ឋ និងតម្លៃពាណិជ្ជកម្ម។ក្នុងន័យនេះ ការប្រើប្រាស់ពូជមានគុណភាពគឺត្រូវបាន និងកំពុងក្លាយជាអត្ថប្រយោជន៍ដ៏សំខាន់ដើម្បីបង្កើនផលិតភាព និងទិន្នផលជាមួយនិងការដាំដុះដំណាំស្រូវតាមបែបទំនើបជាមួយគ្នា។

មានប្រធានក្រុមផលិតពូជម្នាក់ក្នុងខេត្តបាត់ដំបងក្រោមជំនួយរបស់គម្រោងបានឈ្នះពានរង្វាន់″បច្ចេកទេសផលិតកម្មពូជមានគុណភាពខ្ពស់″ នៅក្នុងកម្មវិធី″ការប្រលងកសិករឆ្នើមប្រចាំឆ្នាំ២០១៣″ដែលឧបត្ថម្ភគ្រាំទ្រដោយនាយកដ្ឋានកសិកម្មនៃMAFF។ វាជាភាពជោគជ័យមួយក្នុងនាមជាគម្រោងដែលខំប្រឹងប្រែងកែលម្អរផលិតកម្មពូជ និងត្រូវបានផ្សព្វផ្សាយជាសាធារណៈក្នុងប្រទេសកម្ពុជា។

យើងខ្ញុំសង្ឃឹមថាសៀវភៅនេះនិងជួយក្នុងការប្រើប្រាស់ចំពោះផលិតនូវពូជស្រូវមានគុណភាពល្អក្នុងការចូលរួមចំណែកដើម្បីនិរន្តរភាពផ្នែកផលិតកម្មពូជស្រូវ។

លោក **តាស៊ុអូ ហ្វូជីតា** ជំនាញការផ្នែកគ្រប់គ្រងកសិកដ្ឋាន និងផលិតកម្មពូជ
លោក **ផៃ ពិសិដ្ឋ** ជំនួយការគម្រោង
**គម្រោងបង្កើនផលិតភាព កសិកម្មក្នុងតំបន់ទន្លេសាបប៉ែកខាងលិច(APPP)**

ធ្វើនៅបាត់ដំបង ខែធ្នូ ឆ្នាំ២០១៤ នៃ**ព្រះរាជាណាចក្រកម្ពុជា**

# មាតិកា




អារម្ភកថា

**ផ្នែកទី I** គម្រោងការនៃផលិតកម្មពូជស្រូវ

1-1 សេចក្តីណែនាំ ........ 4
1-2 ការចាត់ចំណាត់ថ្នាក់ពូជស្រូវ ........ 5
1-3 ពូជស្រូវណែនាំជាផ្លូវការក្នុងប្រទេសកម្ពុជា ........ 6
1-4 ដំណើរការផលិតកម្មពូជ និងការចុះអធិការកិច្ច ........ 7

**ផ្នែកទី II** ការលាងសំអាតពូជ និងការគ្រប់គ្រងសំណាប

2-1 ការលាងសំអាតពូជដោយល្បាយទឹកជីអ៊ុយរ៉េដើម្បីជ្រើសរើសពូជ
(1) របៀបរៀបចំល្បាយជីអ៊ុយរ៉េ ........ 9
(2) របៀបជ្រើសរើសគ្រាប់ពូជស្រូវពេញ ........ 10
2-2 ហេតុអ្វីបានជាគ្រាប់ពូជពេញមានសារសំខាន់? ........ 11
2-3 ការលាងសំអាតពូជដោយទឹកក្តៅដើម្បីសម្លាប់មេរោគ ........ 12
2-4 ការត្រាំ និងផ្អាប់ពូជ ........ 13
2-5 ការផលិតឬងអង្កាម ........ 14
2-6 ការរៀបចំថ្នាលសំណាប និងសាប ........ 15
2-7 ការធ្វើឲ្យសំណាបរឹងមាំ ........ 16
2-8 ការទប់ស្កាត់កត្តាចង្រៃនៅដំណាក់កាលសំណាប
(1) ជំងឺផ្សិតស្រូវ ........ 17
(2) ទ្រីប ........ 18

**ផ្នែកទី III** ការអនុវត្តការដាំដុះនៅឯស្រែ

3-1 ការរៀបចំដី
(1) ការភ្ជួរ និងរាស់បំបែកដី ........ 20
(2) ការកៀរដីឲ្យស្មើ ........ 21
3-2 ការបាចជីទ្រាប់បាត ........ 22
3-3 ការស្ទូង ........ 23
3-4 ការសំអាតស្មៅ ........ 24
3-5 ការបាចជីបំប៉នលើកទី១ ........ 25
3-6 ការដាក់ជីបំប៉នលើកទី២ ........ 26
3-7 វិនិច្ឆ័យពេលវេលាក្នុងការច្រូតកាត់ ........ 27
3-8 ការច្រូតកាត់ ........ 28

**ផ្នែកទី IV** ការចុះអធិការកិច្ចតាមស្រែ និងដកប្រភេទពូជលាយ

4-1 កាលវិភាគពង្រៀងនៃការចុះអធិការកិច្ចតាមស្រែ ........ 30
4-2 ការរៀបចំស្រែ ........ 31
4-3 លក្ខណៈវិនិច្ឆ័យអធិការកិច្ច
(1) គ្រាប់ពូជសុទ្ធទទួលស្គាល់ ........ 32
(2) គ្រាប់ពូជសុទ្ធអនុញ្ញាត ........ 33
4-4 ការកំណត់ប្រភេទពូជលាយ និងពូជផ្សេងគ្នា ........ 34

**ផ្នែកទី V** បច្ចេកទេសទុកដាក់ក្រោយពេលប្រមូលផលរួច

5-1 ការហាលសម្ងួត ........ 36
5-2 ការបក់សំអាត និងច្រក ........ 37
5-3 ស្តង់ដារគុណភាពពូជស្រូវជាពង្រៀង ........ 38
5-4 ការធ្វើតេស្តិ៍ដំណុះ ........ 39

**ឧបសម្ព័ន្ធ**

1 តារាងចុះអធិការកិច្ច 1&2 ........ 41
2 តារាងចុះអធិការកិច្ច 3&4 ........ 42
3 តារាងជម្ងឺ និងថ្នាំកំចាត់ជម្ងឺ ........ 43
4 តារាងសត្វល្អិត និងថ្នាំកំចាត់សត្វល្អិត ........ 44
5 ថ្នាំកំចាត់ស្មៅសំរាប់ដំណាំស្រូវដែលអាចរកបានក្នុងទីផ្សារកម្ពុជា ........ 45
6 ពត៌មានទំនាក់ទំនង ........ 46

# ផ្នែកទី I. គម្រោងការនៃផលិតកម្មពូជស្រូវ



# 1-1. សេចក្តីណែនាំ

## ហេតុអ្វីបានជាយើងចាំបាច់ត្រូវដោះដូរពូជដើម?



ទិន្នផល ហើយនិងគុណភាពធ្លាក់ចុះដោយសារតែភាពក្លាយរបស់ពូជ ប្រសិនបើពូជត្រូវបានប្រើប្រាស់ដដែលៗជារៀងរាល់ឆ្នាំ។ ការធ្លាក់ចុះគុណភាពរបស់ពូជកើតមានប្រហែលជាឆ្នាំទី៣បន្ទាប់ពីដោះដូរពូជដើម។

## ហេតុអ្វីបានជាវាមានសារៈសំខាន់ចំពោះការប្រើប្រាស់ពូជមានគុណភាពល្អ?



ប្រើប្រាស់ពូជមានគុណភាពល្អគឺមានសារៈសំខាន់ណាស់ដើម្បីរក្សាបាននូវទិន្នផល និងគុណភាពពូជ។ វាក៏មានសារៈសំខាន់ផងដែរដើម្បីបញ្ចៀសការចម្លងជម្ងឺតាមគ្រាប់ពូជ។



# 1-2. ការចាត់ចំណាត់ថ្នាក់នៃពូជស្រូវ



| | |
|---|---|
| គ្រាប់ពូជសុទ្ធនៃជំរើសវិទូដោយវិទ្យាស្ថាន CARDI | ប្រភពនៃពូជសុទ្ធផលិតដោយអ្នកបង្កាត់នៃវិទ្យាស្ថាន(CARDI) |
| គ្រាប់ពូជសុទ្ធគ្រឹះដោយវិទ្យាស្ថាន CARDI | កូនចៅនៃគ្រាប់ពូជសុទ្ធនៃជំរើសវិទូផលិតដោយវិទ្យាស្ថានCARDI |
| គ្រាប់ពូជសុទ្ធទទួលស្គាល់ដោយក្រុមកសិករផលិតពូជស្រូវ | កូនចៅនៃគ្រាប់ពូជសុទ្ធគ្រឹះផលិតដោយក្រុមកសិករផលិតពូជស្រូវ |
| គ្រាប់ពូជសុទ្ធអនុញ្ញាតដោយក្រុមកសិករផលិតពូជស្រូវ | កូនចៅនៃគ្រាប់ពូជសុទ្ធទទួលស្គាល់ផលិតដោយក្រុមកសិករផលិតពូជស្រូវ |
| ការដាំដុះស្រូវធម្មតាដោយប្រជាកសិករ | គ្រាប់ពូជសុទ្ធអនុញ្ញាតគឺត្រូវបានប្រើប្រាស់ដោយប្រជាកសិករ |



# 1-3 ពូជស្រូវណែនាំជាផ្លូវការក្នុងប្រទេសកម្ពុជា



ការប៉ាន់ប្រមាណរដូវកាលដាំដុះស្រូវនៅក្នុងប្រទេសកម្ពុជា




ពូជស្រូវណែនាំជាផ្លូវការក្នុងប្រទេសកម្ពុជា

| ពូជស្រូវស្រាល | ពូជស្រូវកណ្តាល | ពូជស្រូវធ្ងន់ |
|---|---|---|
| អ៊ីរ៉ែ៦៦ | ផ្ការំដួល | រាំងជ័យ |
| ជលសារ | ផ្ការំដេង | ខា៤ |
| សែនពីដោរ | ផ្ការមៀត | ខា៦ |
| | ផ្កាច័ន្ទសែនសរ | |

គ្រាប់ពូជស្រូវសុទ្ធគ្រឹះទាំង១០មុខដែលបានណែនាំជាផ្លូវការគឺត្រូវបានផលិត និងចែកចាយដោយវិទ្យាស្ថានCARDI ។

នៅក្នុងខេត្តគោលដៅរបស់គម្រោងAPPP ពូជស្រូវផ្ការំដួលគឺត្រូវបានដាំដុះសឹងតែ១០០%នៅតំបន់វាលរាបនៃផលិតកម្មពូជ។

# 1-4 ផលិតកម្មពូជស្រូវ និងដំណើរការនៃការចុះអធិការកិច្ច

ដំណើរការនៃការចុះអធិការកិច្ច

| អធិការកិច្ចតាមស្រែលើកទី១ | អធិការកិច្ចតាមស្រែលើកទី២ | អធិការកិច្ចតាមស្រែលើកទី៣ | អធិការកិច្ចតាមស្រែលើកទី៤ | អធិការកិច្ចផលិតផលសម្រេច |
|---|---|---|---|---|







| | | | | |
|---|---|---|---|---|
| ជាប់ | ជាប់ | ជាប់ | ជាប់ | ជាប់ |

ដំណាក់កាលលូតលាស់របស់ស្រូវ


សំណាប


ការស្ទូង


ចេញក្បួរ


ទុំ


ច្រូតកាត់


ស្រូវពូជ

ធ្លាក់ ធ្លាក់ ធ្លាក់ ធ្លាក់ ធ្លាក់ → ស្រូវចំណី

# ផ្នែកទី II. ការលាងសំអាតពូជ និងការគ្រប់គ្រងថ្នាលសំណាប



# 2-1 ការលាងសំអាតពូជដោយទឹកជីអ៊ុយរ៉េដើម្បីជ្រើសរើសពូជ
## (1) របៀបរៀបចំល្បាយទឹកជីអ៊ុយរ៉េ











② ដាក់ចូលក្នុងទឹកថ្លាធម្មតាចំនួន៤០លីត្រ។

③ កូរទឹករហូតដល់ជីរលាយអស់។

④ ដាក់ពងមាន់ឬពងទាចូលក្នុងល្បាយជីអ៊ុយរ៉េដើម្បីពិនិត្យមើលកំហាប់ទឹកជីដាក់លាក់។

① រៀបចំជីអ៊ុយរ៉េចំនួន២០គ.ក្រ។





ល្បាយអំបិលអាចជំនួសឲ្យល្បាយអ៊ុយរ៉េបាន។ ប្រើអំបិល៨គ.ក្រសំរាប់ទឹក៤០លីត្រ។

ល្បាយជីអ៊ុយរ៉េគឺមានសារធាតុពុល។ រក្សាទុកឲ្យឆ្ងាយពីក្មេង និងសត្វពាហន:។

# 2-1 ការលាងសំអាតពូជដោយប្រើទឹកជីអ៊ុយរ៉េដើម្បីជ្រើសរើសពូជ

## (2) របៀបជ្រើសរើសគ្រាប់ពូជពេញ



គ្រាប់ស្កៀតមួយចំនួន
លាយក្នុងពូជស្រូវ



គ្រាប់ពេញ
ទាំងអស់



① ត្រៀមគ្រាប់ពូជសុទ្ធ ទទួលស្គាល់រួចរាល់



② ដាក់ពូជស្រូវ ចូលក្នុងការ៉ុង សំណាញ់



③ ដាក់ពូជស្រូវក្នុង ការ៉ុងសំណាញ់ ចូលក្នុងទឹកជី អ៊ុយរ៉េ។ កូរគ្រាប់ ពូជដែលដាក់ ចូលក្នុងទឹកជី អ៊ុយរ៉េឲ្យសព្វ។



④ ដួសគ្រាប់ អណ្តែតចេញ



⑤ លាងគ្រាប់ពូជដោយទឹក ស្អាត។ ស្រង់បង្ហូរទឹកពី ការ៉ុងសំណាញ់ឲ្យអស់ ដើម្បីឈានទៅជំហាន បន្ទាប់។

# 2-2 ហេតុអ្វីបានជាគ្រាប់ពូជពេញចាំបាច់?



ហេតុអ្វីបានជាយើងត្រូវការប្រើប្រាស់គ្រាប់ពូជពេញ?




មានដំណុះល្អ



លូតលាស់មានសុខភាពល្អ



កាត់បន្ថយជម្ងឺ



បង្កើនទិន្នផល



# 2-3 ការលាងសំអាតពូជដោយទឹកក្តៅដើម្បីសម្លាប់មេរោគ





① ដាំទឹកឲ្យក្តៅដោយប្រើទឹកស្អាត




② រក្សាសីតុណ្ហភាពទឹកឲ្យនៅត្រឹមតែ៦០អង្សារសេ។ ពិនិត្យមើលសីតុណ្ហភាពទឹកដោយប្រើឧបករណ៍វាស់កំដៅ។




③ ដាក់គ្រាប់ពូជស្រូវចូលក្នុងទឹកក្តៅនូវកំរិតជាក់ត្រឹមតែ៦០អង្សារសេ រយៈពេល១០នាទី។ គ្រលែង ការ៉ុងពូជថ្នមៗគ្រប់ពេលវេលា។



④ យកការ៉ុងពូជចេញពីទឹកក្តៅបន្ទាប់ពីបានរយៈពេល១០នាទី។ ដាក់ចូលក្នុងទឹកធម្មតាដើម្បីឲ្យវាត្រជាក់។



⑤ ស្រង់បង្ហូរទឹកចេញ។ ចូរកុំដាក់ពូជលើដីផ្ទាល់ឲ្យសោះ។



⑥ គម្រោងAPPPសូមធ្វើការណែនាំឲ្យយកពូជទៅត្រាំ និងផ្កាប់បន្ទាប់ពីដំណើរការសម្លាប់មេរោគដោយទឹកក្តៅនេះរួច។

# 2-4 ការត្រាំ និងផ្អាប់ពូជ





ត្រាំពូជដែលលាងសំអាតរួចក្នុងទឹកធម្មតា ហើយស្អាតរយៈពេល២៤ម៉ោង។



ដាក់ផ្អាប់ពូជកន្លែងណាដែលស្អាតរយៈពេល៤៨ម៉ោង ហើយគ្របអ្វីមួយពីលើដើម្បីឲ្យវាក្តៅឧណ្ហៗ។



ពិនិត្យមើលពន្លកដុះពី១-២ម.ម។ ការផ្អាប់អាចបន្តរយៈមួយថ្ងៃទៀតបើពន្លកដុះនៅខ្លីពេក។

# 2-5 ការផលិតធ្យូងអង្កាម



① រៀបចំចង្ក្រាន និងបំពង់ផ្សែង។ ធុងចំណុះ១៨លីត្រអាចប្រើប្រាស់ជាចង្ក្រានបាន។



② បង្កាត់ភ្លើងក្នុងចង្ក្រាន។



③ ត្រូវប្រាកដថាភ្លើងឆេះបានល្អ។



④ ស៊កបំពង់ផ្សែងខាងលើចង្ក្រាន។



⑤ គ្របអង្កាមស្ងួតពីលើចង្ក្រាន។



⑥ អ្នកអាចដុតធ្យូងអង្កាមជាលក្ខណៈចំហរ ឬក្នុងធុងបាន។



⑦ នៅពេលផ្នែកនៃផ្ទៃពំនូកប្រែក្លាយពណ៌ខ្មៅ ត្រូវត្រឡប់អង្កាមចូល។



⑧ នៅពេលអង្កាមប្រែក្លាយជាពណ៌ខ្មៅអស់ ហើយនោះ ត្រូវស្រោចទឹកដើម្បីពន្លត់វា។





ផេះ

⑨ សម្ងួតធ្យូងអង្កាមឲ្យស្ងួត ហើយរក្សាទុកក្នុងការ៉ុងសំរាប់ប្រើប្រាស់នាថ្ងៃខាងមុខ។

# 2-6 ការរៀបចំថ្នាលសំណាប និងសាប




① គម្រោងAPPPណែនាំក្រុមផលិតពូជស្រូវរៀបចំថ្នាលសំណាបនូវទំហំបណ្តោយ ១.២ម ដែលមានចន្លោះ ៣០-៥០ស.ម។



② ដាក់ធ្យូងអង្កាមលើថ្នាលសំណាប (ប្រហែលជា ១ការ៉ុង/១០ម$^{២}$)។ ដាក់ជីកំប៉ុស្តិ៍ ប្រសិនបើមាន។



③ ច្របល់ធ្យូងអង្កាមជាមួយនិងដី។



④ កៀរថ្នាលសំណាបឲ្យស្មើ។




⑤ បាចជីដេអាប៉េ (18-46-00)នៅអត្រា ៩ក្រាម/ម$^{២}$។



⑥ ព្រោះគ្រាប់ស្រូវដុះលើថ្នាលសំណាប។ គម្រោងបានណែនាំនូវអត្រាគ្រាប់៥០ក្រាម/ម$^{២}$។

# 2-7 ការធ្វើឲ្យដើមសំណាបរឹងមាំ

ដើមសំណាបដុះស្លឹកខ្ទង់ជា ៣-៤ស្លឹក និងរួចរាល់ក្នុងការស្ទូង នូវអាយុសំណាប២០ថ្ងៃបន្ទាប់ពីសាបរួច។

ពិនិត្យមើលស្តង់ដារអត្រាគ្រាប់ពូជ ដើម្បីធ្វើឲ្យសំណាបមានសុខភាពល្អ។ បញ្ចៀសការបញ្ចូលទឹកលើសចំណុះ ដើម្បីកុំឲ្យសំណាបរៀវស្គួច និងមិនរឹងមាំ។

យ៉ាងណាមិញ ចុងសំណាបរៀវស្គួចគួរតែកាត់ចេញដើម្បីស្ទូងដូចការអនុវត្តតាមទំលាប់ដែរ។






# 2-8 ការទប់ស្កាត់កត្តាចង្រៃនៅដំណាក់កាលសំណាប

## (1) ជំងឺផ្សិតស្រូវ



**តើជំងឺផ្សិតស្រូវជាអ្វី?**

ជំងឺផ្សិតស្រូវគឺបង្កឡើងដោយពពួកផ្សិត។





**តើវាកើតឡើងយ៉ាងដូចម្តេច?**

ពូជស្រូវគឺជាប្រភពជំងឺដំបូងគេ បង្កស់ នៅពេលដែលប្រជាកសិករបានប្រមូលផលស្រូវពីស្រែដែលបានឆ្លងជំងឺផ្សិតស្រូវ។



ស្លឹក ដើម និងស្មៅដែលបានឆ្លងជំងឺនេះក៏ជាប្រភពនៃការចម្លងជំងឺដែរ។








**តើត្រូវទប់ស្កាត់វាយ៉ាងដូចម្តេច?**

- ✓ ប្រើប្រាស់ពូជដែលធន់ទ្រាំនិងជំងឺ ហើយត្រូវលាងសំអាតពូជ។
- ✓ អនុវត្តន៍តាមវិធីសាស្ត្រជ្រើសរើសពូជ និងសម្លាប់មេរោគសមស្រប ជាពិសេស រយៈពេលត្រាំពូជ ហើយនិងកំរិតសីតុណ្ហភាពក្នុងការលាងសម្អាតពូជដោយទឹកក្តៅ។
- ✓ បញ្ចៀសការប្រើប្រាស់អាសូតលើសចំណុះ។
- ✓ ត្រូវប្រាកដថាមានខ្យល់ចេញចូលល្អនៅក្នុងទីសំណាប និងស្រែសន្ទូង។
- ✓ ប្រើប្រាស់ថ្នាំគីមីសមស្របសំរាប់ការទប់ស្កាត់ជំងឺ និងកត្តាចង្រៃ។
  ឧទា.) ថ្នាំសាវន្ត/ SAWANT ( Isoprothiolane 40%)
- ✓ មិនត្រូវស្ទូងសំណាបដែលបានឆ្លងជំងឺឡើយ។
- ✓ ដកសំណាបដែលបានឆ្លងជំងឺធ្ងន់ធ្ងរចោល អាចយកទៅដុត ឬកប់ចោល។

# 2-8 ការទប់ស្កាត់កត្តាចង្រៃនៅដំណាក់កាលសំណាប

## (2) ទ្រីប






ទ្រីបគឺជាសត្វល្អិតទូទៅដែលតែងតែ ឃើញមាននៅក្នុងទីសំណាប។ ពួកវា បំផ្លាញសំណាបដោយការជញ្ជក់យក ទឹក។



សំណាបនិងរមូរ ហើយងាប់ បន្ទាប់ពី មានការបំផ្លាញដោយទ្រីប។



ចាប់សត្វទ្រីបតាមទីសំណាបដោយ ប្រើមុងសំណាញ់។





# ផ្នែកទីIII. ការអនុវត្តការដាំដុះក្នុងទីស្រែ



# 3-1 ការរៀបចំដី

## (1) ភ្ជួរ និងរាស់បំបែកដី










- ចាប់ផ្ដើមភ្ជួរ នៅពេលដីស្រែមានសំណើមគ្រប់គ្រាន់។
- ការភ្ជួរដីគួរតែធ្វើឡើងយ៉ាងហោចណាស់ពីរដង ហើយឲ្យស្មៅត្រឡប់កប់ចូលក្នុងដីប្រយោជន៍ដើម្បីទប់ស្កាត់ស្មៅដុះ។
- គួរតែភ្ជួរដីយ៉ាងហោចណាស់ឲ្យបានជម្រៅ១៥ – ១៨ស.ម ដើម្បីឲ្យដំណាំអភិវឌ្ឍន៍ប្រព័ន្ធឫសបានល្អ។



- បញ្ចូលទឹកពន្លិចស្រែ ហើយចាប់ផ្ដើមរាស់បំបែកដី។
- ការរាស់បំបែកដីជាការអនុវត្តដោយបំបែកដីដុំៗ និងជាការច្របល់ដីហើយ និងទឹកចូលគ្នាឲ្យបានស្មើល្អ។



# 3-1 ការរៀបចំដី

## (2) ការកៀរពង្រាបឲ្យស្មើរ

**ការរៀបចំដីជាកត្តាសំខាន់បំផុតសំរាប់ផលិតកម្មពូជ**



ការលូតលាស់របស់ដំណាំមិនបានស្មើរ នៅពេលដែលការកៀរព្រាបដីមិនបានល្អ

ការផ្គត់ផ្គង់ទឹកគឺមិនបានស្មើរគ្នា

កន្លែងមួយចំនួនទទួលបានទឹកច្រើន រីឯកន្លែងខ្លះទទួលបានតិចឬអត់



**ការកៀរពង្រាបដីគឺជាផ្នែកមួយដ៏ដំខាន់ដើម្បីទទួលបានគុណភាពផលិតកម្មពូជខ្ពស់**



ការរៀបចំដីបានល្អធ្វើឲ្យដំណាំលូតលាស់បានស្មើរល្អ និងផ្គត់ផ្គង់ទឹកស្មើរគ្នាៗ



# 3-2 ការដាក់ជីទ្រាប់បាត

កែតម្រូវចំនួនជីអាស្រ័យលើស្ថានភាពដំណាំក្នុងស្រែរបស់អ្នក។






ក្នុងជី១០០គ.ក្រមានសារធាតុ N:១៨គ.ក្រ P:៤៦គ.ក្រ និងK:០គ.ក្រ

- បាចជីដេអាប៉េមួយការ៉ុងក្នុងផ្ទៃដីមួយហិចតា(៥០គ.ក្រ)សំរាប់ទ្រាប់បាត។
- កំរិតសារធាតុចញ្ចឹមរបស់ជីអសរីរាង្គគឺត្រូវបានសរសេរខាងលើសំបកការ៉ុង ឧទា. "NPK 18-46-00" មានន័យថា N18%,P($P_2O_5$)46%, K($K_2O$)0%។
- ជីដេអាប៉េមួយការ៉ុងមាន N:9kg, $P_2O_5$:23kg, $K_2O$:0kg/ហ.ត។

តារាងរង្វាស់រង្វាល់រ៉ៃទៅជាហិចតា

| រ៉ៃ | ហិចតា | ចំនួនជីដេអាប៉េ(kg) |
|---|---|---|
| 1 0 | 1.60 | 80 |
| 9 | 1.44 | 72 |
| 8 | 1.28 | 64 |
| 7 | 1.12 | 56 |
| 6 | 0.96 | 48 |
| 5 | 0.80 | 40 |
| 4 | 0.64 | 32 |
| 3 | 0.48 | 24 |
| 2 | 0.32 | 16 |
| 1 | 0.16 | 8 |

តារាងរង្វាស់រង្វាល់ហិចតាទៅជាអា

| ហិចតា | អា | ចំនួនជីដេអាប៉េ(kg) |
|---|---|---|
| 100 | 50 | |
| 0.9 | 90 | 45 |
| 0.8 | 80 | 40 |
| 0.7 | 70 | 35 |
| 0.6 | 60 | 30 |
| 0.5 | 50 | 25 |
| 0.4 | 40 | 20 |
| 0.3 | 30 | 15 |
| 0.2 | 20 | 10 |
| 0.1 | 10 | 5 |
| 0.01 | 1 | 0.5 |

# 3-3 ការស្ទូង





① ដកសំណាបដែលមានអាយុពី ១៨ - ២០ថ្ងៃយកមកស្ទូង។




② រៀបចំខ្សែដោយដាក់សញ្ញាសំគាល់ ២០ស.មក្នុងមួយចន្លោះៗ។ ស្ទូងជាជួរនូវចន្លោះ២០ស.ម។



③ ស្ទូងសំណាប១ដើមក្នុងមួយគុម្ព។ ស្ទូងជម្រៅក្នុងដីប្រហែលជា ២-៣ស.ម។




④ បន្ទាប់ពីស្ទូងបញ្ចប់មួយជួរហើយ បន្តទៅជួរបន្ទាប់។



⑤ ត្រូវរក្សាជម្រៅទឹកប្រហែល៣-៥ស.ម បន្ទាប់ពីស្ទូងរួច។



⑥ បន្ទាប់ពីស្ទូងរួច១ឬ២សប្តាហ៍ ត្រូវស្ទូងជួសចន្លោះគុម្ពដែលដាច់។ បំបែកដើមពីគុម្ពសន្ទូងដែលស្ទូងរួច។

# 3-4 ការគ្រប់គ្រងស្មៅ





ស្រែគ្មានស្មៅ







ស្រែស្មៅច្រើន

- សម្អាតស្មៅតាំងតែពីដំណាក់កាលលូតលាស់ដំបូង។
- ស្មៅប្រកួតប្រជែងនិងស្រូវដូចជាពន្លឺព្រះអាទិត្យ ជីជាតិ និងទឹក ហើយពួកវាលូតលាស់លឿនជាងស្រូវណាស់។
- សម្អាតស្មៅដើម្បីកាត់បន្ថយទីជំរករបស់សត្វល្អិត និងពពួកផ្សិត។
- រក្សាជម្រៅទឹកប្រហែល៥ស.ម ឬផ្ទៃដីមានទឹកជោគជាំដើម្បីការពារការលូតលាស់របស់ស្មៅ។
- ប្រសិនបើបាញ់ថ្នាំស្មៅ ត្រូវបាញ់នូវដំណាក់កាលស្មៅដុះស្លឹក២-៣។
- នៅពេលស្មៅផលិតជាគ្រាប់ កំរិតស្មៅនិងច្រើនឡើងៗនៅរដូវកាលបន្ទាប់។
- សម្អាត/កាត់ស្មៅតាមភ្លឺស្រែ។
- ព្យាយាមរក្សាស្រែដោយគ្មានស្មៅ។

# 3-5 ការបាចជីបំប៉នលើកទី១



- បាចជីអ៊ុយរ៉េមួយការ៉ុងក្នុងផ្ទៃដីមួយហិចតា (៥០គ.ក្រ/ហ.ត)សំរាប់បំប៉នលើកទីមួយមានដូចតទៅនេះ :
  ពូជស្រូវស្រាល :១៥ - ២០ថ្ងៃបន្ទាប់ពីស្ទូងរួច។
  ពូជស្រូវកណ្តាល : ៣០ថ្ងៃបន្ទាប់ពីស្ទូងរួច។
  ពូជស្រូវធ្ងន់ ៣០- ៤០ថ្ងៃបន្ទាប់ពីស្ទូងរួច។
- ជីអ៊ុយរ៉េមានសារធាតុ N46%,P($P_2O_5$)0%, K($K_2O$)0%។
- ជីអ៊ុយរ៉េមួយការ៉ុងមានសារធាតុ N:9kg, $P_2O_5$:23kg, $K_2O$:0kg/ហ.ត។




តារាងរង្វាស់រង្វាល់រ៉ៃទៅជាហិចតា

| រ៉ៃ | ហិចតា | ចំនួនជីអ៊ុយរ៉េ(kg) |
|---|---|---|
| 10 | 1.60 | 80 |
| 9 | 1.44 | 72 |
| 8 | 1.28 | 64 |
| 7 | 1.12 | 56 |
| 6 | 0.96 | 48 |
| 5 | 0.80 | 40 |
| 4 | 0.64 | 32 |
| 3 | 0.48 | 24 |
| 2 | 0.32 | 16 |
| 1 | 0.16 | 8 |

តារាងរង្វាស់រង្វាល់ហិចតាទៅជាអា

| ហិចតា | អា | ចំនួនជីអ៊ុយរ៉េ(kg) |
|---|---|---|
| 1.0 | 100 | 50 |
| 0.9 | 90 | 45 |
| 0.8 | 80 | 40 |
| 0.7 | 70 | 35 |
| 0.6 | 60 | 30 |
| 0.5 | 50 | 25 |
| 0.4 | 40 | 20 |
| 0.3 | 30 | 15 |
| 0.2 | 20 | 10 |
| 0.1 | 10 | 5 |
| 0.01 | 1 | 0.5 |

# 3-6 ការបាចជីបំប៉នលើកទី២



- បាចជីអ៊ុយរ៉េមួយការ៉ុងក្នុងមួយហិចតា(៥០គ.ក្រ/ហ.ត)សំរាប់បំប៉នលើកទី២នៅដំណាក់កាល២០ថ្ងៃមុនចេញកួរ។
- កំណត់រយៈពេលបាចជីបំប៉នលើកទី២ដោយពិនិត្យមើលកំណកំណើតកួរខ្ចី។ ប្រវែងកំណកំណើតកួរខ្ចីគួរតែ១-២ម.ម។
- ជីអ៊ុយរ៉េមានសារធាតុ N46%,P(P2O5)0%, K(K2O)0%
- មួយការ៉ុងជីអ៊ុយរ៉េមានសារធាតុ
  N:9kg, P2O5:23kg, K2O:0kg/ហ/ត។








បន្ថយចំនួនជីអ៊ុយរ៉េដែលត្រូវបាច នៅពេលពណ៌ស្លឹកឡើងខៀវខ្មៅ។



វាអាចនិងបញ្ឈប់ការបាចជីបំប៉នលើកទី២ នៅពេលដែលពណ៌ស្លឹកស្រូវឡើងខៀវខ្មៅ ហើយកម្ពស់ដើមខ្ពស់ខ្លាំង។ ការប្រើជីអាសូតលើសចំណុះអាចទទួលលទ្ធផលនូវការដួលរលំដើមស្រូវបាន។



# 3-7 លក្ខណៈវិនិច្ឆ័យពេលវេលាក្នុងការប្រមូលផល



គម្រោងAPPPធ្វើការណែនាំដល់ក្រុមកសិករផលិតពូជឲ្យច្រូតកាត់ស្រូវនៅពេលដែលកួរស្រូវប្រែពណ៌លឿង ពី៨០– ៨៥%។




ប្រភពពី : IRRI

ដំណាក់កាលស្រូវទុំ
① ៨០ – ៨៥% នៃកួរស្រូវប្រែជាពណ៌លឿង (ពណ៌ដើមផងដែរ)។
② កំរិតសំណើមគ្រាប់ស្រូវចន្លោះពី២០ ទៅ ២៥%។
③ ចំនួនថ្ងៃបន្ទាប់ពីស្ទូងរួចខ្ទង់ជា១០០ – ១២០ថ្ងៃសំរាប់ពូជស្រូវស្រាល។
④ ចំនួនបន្ទាប់ពីចេញកួរអាចចន្លោះពី ២៨ – ៣៥ថ្ងៃ។

# 3-8 ការប្រមូលផល





- កណ្តាប់ស្រូវសើមមិនត្រូវគរទុកក្នុងស្រែទេ ពីព្រោះវាអាចរងផលប៉ះពាល់ដល់គុណភាពពូជ។
- គួរតែបន្ថយពេលវេលាក្នុងការទុកកណ្តាប់ដែលបានច្រូតកាត់ក្នុងស្រែ  ពីព្រោះថាការហាលកណ្តាប់ក្នុងស្រែអាចបណ្តាលឲ្យធ្លាក់គុណភាពគ្រាប់ឆាប់រហ័ស។
- ត្រូវប្រាកដថាក្ងួរស្រូវមិនប៉ះដី ត្រូវរក្សាក្ងួរឲ្យស្ងួត។
- ការបោកបែនគួរធ្វើឡើងឲ្យបានឆាប់បន្ទាប់ពីច្រូតកាត់រួច។
- ជាពង្រៀង សំណើមគ្រាប់ស្រូវត្រូវច្រូតគួរតែក្រោម១៨%ដើម្បីបញ្ចៀសការកែប្រែពណ៌។





# ផ្នែកទីIV.  ការចុះអធិការកិច្ចតាមស្រែ និងការដកប្រភេទពូជលាយចេញ



# 4-1 ការលវិភាគពង្រៀងនៃការចុះអធិការកិច្ចតាមស្រែ



## ការលវិភាគពង្រៀងនៃការចុះអធិការិច្ចតាមស្រែ និងសាលារៀនស្រែកសិករ(FFS) (ពូជស្រូវផ្ការំដួល)




គំរូប្រភេទពូជលាយ (ត្រូវតែដកចេញ)



(Phil Rice)

* លក្ខណៈវិនិច្ឆ័យនៃអធិការកិច្ចសំរាប់គ្រាប់ពូជសុទ្ធអនុញ្ញាត

# 4-2 ការរៀបចំតាមស្រែ







- សមាជិកម្នាក់អាចផលិតពូជបានត្រឹមមួយមុខ មិនលើសពី ពីរមុខឡើយ ដើម្បីបញ្ចៀសការលាយឡំពូជផ្សេងទៀត។
- ត្រូវប្រាកដថាអ្នក និងកសិករជិតខាងរបស់អ្នកមិនដាំដុះ ប្រភេទពូជស្រូវផ្សេងគ្នាដែលពេលវេលាចេញផ្កាដូចគ្នា ជិតគ្នានិងស្រែផលិតពូជឲ្យសោះដើម្បីបញ្ចៀសការបង្កាត់គ្នា។.
- ស្លាកព័ត៌មានត្រូវតែដាក់បង្ហាញតាមស្រែផលិតកម្មពូជ ដែលមានព័ត៌មានដូចតទៅ:

① ឈ្មោះអ្នកផលិត
② លេខកូដសមាជិកក្នុងក្រុម
③ ឈ្មោះពូជស្រូវ
④ ចំណាត់ថ្នាក់ពូជស្រូវ (ប្រភពពូជ)
⑤ ថ្ងៃសាប
⑥ ថ្ងៃស្ទូង



# 4-3 លក្ខណៈវិនិច្ឆ័យនៃអធិការកិច្ច

## (1) គ្រាប់ពូជស្រូវសុទ្ធទទួលស្គាល់



| | | |
|---|---|---|
|  | អធិការកិច្ចលើកទី ១<br>ដំណាក់កាលសំណាប | ① នៅដាច់ដោយឡែកពីពូជផ្សេងទៀត យ៉ាងហោចណាស់១០ម.ប្រសិនបើរំពឹងថា ថ្ងៃចេញផ្កាដូចគ្នា។<br>② ការលូតលាស់ស្មើរគ្នា យ៉ាងហោចណាស់៨០%។<br>③ ការបំផ្លាញដោយសារសត្វល្អិត និងជំងឺតិចតួច (កំរិតធន់ទ្រាំបាន)។<br>④ គ្មានពូជលាយ។ |
|  | អធិការកិច្ចលើកទី ២<br>៣០ថ្ងៃបន្ទាប់ពីស្ទូង | ① ការលូតលាស់៨០% (យ៉ាងហោចណាស់)។<br>② ជំងឺបាកាណាក្នុងស្រែ០%។<br>③ ជំងឺបាកាណាក្នុងស្រែកសិករជិតខាង ១ដើមក្នុង១០០ម² ក្នុងចំណោម៥០ម។<br>④ សត្វល្អិត និងជំងឺបំផ្លាញ១០% (កំរិតធន់ទ្រាំបាន)។<br>⑤ ពូជលាយ ១ដើមក្នុង១០០ម²។<br>⑥ ស្ទូងជាជួរពី១-២ដើមក្នុងមួយគុម្ព |
|  | អធិការកិច្ចលើកទី ៣<br>ដំណាក់កាលចេញក្បួរ | ① នៅដាច់ដោយឡែកពីពូជផ្សេងទៀត១០ម. ប្រសិនបើការចេញផ្កាមានរយៈពេល ត្រឹម៧ថ្ងៃ(យ៉ាងហោចណាស់)។<br>② ការលូតលាស់/ចេញក្បួរ៨០%នៃគុម្ព (យ៉ាងហោចណាស់)។<br>③ សត្វល្អិត និងជំងឺបំផ្លាញ១០% (កំរិតធន់ទ្រាំបាន)។<br>④ មានលាយពូជផ្សេង ១ដើមក្នុង១០០ម²។ |
|  | អធិការកិច្ចលើកទី ៤<br>ដំណាក់កាលស្រូវទុំ | ① សត្វល្អិត និងជំងឺបំផ្លាញ១០% (កំរិតធន់ទ្រាំបាន)។<br>② មានលាយពូជផ្សេង ១ដើមក្នុង១០០ម²។ |
|  | អធិការកិច្ចលើកទី ៥<br>អធិការកិច្ចផលិតផល | ① ពូជសុទ្ធ៩៨%(អប្បបរមា) កំទេចកំទី ២%(អតិបរមា) គ្រាប់ស្មៅ0.0៥%(អតិបរមា)<br>② លាយពូជផ្សេងទៀត0.១%(អតិបរមា)។<br>③ កំរិតសំណើម១៣%(អតិបរមា)។<br>④ អនុបាតគ្រាប់ពេញ: ៩៥% (អប្បបរមា)។ |

# 4-3 លក្ខណៈវិនិច្ឆ័យនៃអធិការកិច្ច
## (2) គ្រាប់ពូជសុទ្ធអនុញ្ញាត



| | | |
|---|---|---|
|  | អធិការកិច្ចលើកទី ១<br>ដំណាក់កាលសំណាប | ① នៅដាច់ដោយឡែកពីពូជផ្សេងទៀត យ៉ាងហោចណាស់៥ម.ប្រសិនបើ រំពឹងថាថ្ងៃចេញផ្កាដូចគ្នា។<br>② ការលូតលាស់ស្មើរគ្នា យ៉ាងហោចណាស់៨០%។<br>③ ការបំផ្លាញដោយសារសត្វល្អិត និងជំងឺតិចតួច (កំរិតធន់ទ្រាំបាន)។<br>④ គ្មានពូជលាយ។ |
|  | អធិការកិច្ចលើកទី ២<br>៣០ថ្ងៃបន្ទាប់ពីស្ទូង | ① ការលូតលាស់៧០% (យ៉ាងហោចណាស់)។<br>② ជំងឺបាកាណាក្នុងស្រែ០%។<br>③ ជំងឺបាកាណាក្នុងស្រែកសិករជិតខាង ៥ដើមក្នុង១០០ម$^{២}$ ក្នុងចំណោម៥ម។<br>④ សត្វល្អិត និងជំងឺបំផ្លាញ១០% (កំរិតធន់ទ្រាំបាន)។<br>⑤ ពូជលាយ ៣ដើមក្នុង១០០ម$^{២}$។<br>⑥ ស្ទូងជាជួរពី១-២ដើមក្នុងមួយគុម្ព |
|  | អធិការកិច្ចលើកទី ៣<br>ដំណាក់កាលចេញកួរ | ① នៅដាច់ដោយឡែកពីពូជផ្សេងទៀត៥ម. ប្រសិនបើការចេញផ្កាមានរយៈពេលត្រឹម៧ថ្ងៃ(យ៉ាងហោចណាស់)។<br>② ការលូតលាស់/ចេញកួរ៧០%នៃគុម្ព (យ៉ាងហោចណាស់)។<br>③ សត្វល្អិត និងជំងឺបំផ្លាញ១០% (កំរិតធន់ទ្រាំបាន)។<br>④ មានលាយពូជផ្សេង ៣ដើមក្នុង១០០ម$^{២}$។ |
|  | អធិការកិច្ចលើកទី ៤<br>ដំណាក់កាលស្រូវទុំ | ① សត្វល្អិត និងជំងឺបំផ្លាញ១០% (កំរិតធន់ទ្រាំបាន)។<br>② មានលាយពូជផ្សេង ៣ដើមក្នុង១០០ម$^{២}$។ |
|  | អធិការកិច្ចលើកទី ៥<br>អធិការកិច្ចផលិតផល | ① ពូជសុទ្ធ៩៨%(អប្បបរមា) កំទេចកំទី ២%(អតិបរមា) គ្រាប់ស្មៅ0.0៥%(អតិបរមា)<br>② លាយពូជផ្សេងទៀត0.២%(អតិបរមា)។<br>③ កំរិតសំណើម១៣%(អតិបរមា)។<br>④ អនុបាតគ្រាប់ពេញ: ៩៥% (អប្បបរមា)។ |

# 4-4 ការកំណាត់ពូជលាយ និងពូជផ្សេងគ្នា

ការកំណត់ និងដកពូជលាយចេញគួរតែផ្តើមអនុវត្តន៍តាំងពីដំណាក់កាលសំណាប និងបន្តរហូតដំណាក់កាលស្រូវទុំ។
ការដកពូជលាយដោយការទាញ ឬកាត់ឲ្យដល់គល់នៃគុម្ពស្រូវ។


















# ផ្នែកទី V.  បច្ចេកទេសទុកដាក់ក្រោយពេលប្រមូលផល



# 5-1 ការហាលពូជស្រូវ



① ចាប់ផ្ដើមហាលស្រូវភ្លាមៗបន្ទាប់ពីបោកស្រូវរួច។ ប្រើតង់ប្លាស្ទិកឬស្បៃសំណាញ់។ ត្រូវប្រាកដថាតង់ប្លាស្ទិក ឬស្បៃសំណាញ់ស្អាតដើម្បីបញ្ចៀសការលាយឡំជាមួយស្រូវផ្សេងដោយចៃដន់។



② ធ្វើឲ្យមានផ្នត "កំពូល និងចន្លោះ" ។



③ ប្រែត្រឡប់ស្រូវឲ្យបានញឹកញាប់ដើម្បីហាលស្ងួតស្មើរគ្នា។ ឈប់ហាលនៅពេលដែលកំរិតសំណើមក្រោម១៣%។






# 5-2 ការបក់សំអាត និងច្រកការ៉ុង






① ពិនិត្យកំរិតសំណើមស្រូវមុនចាប់ផ្តើមបក់សំអាត។



② បក់គ្រាប់ស្អៀតចេញ។ កែតម្រូវម៉ាស៊ីនបក់ឲ្យទទួលបានតែគ្រាប់ពេញ។



③ ទម្ងន់៤០គ.ក្រក្នុងមួយការ៉ុង។ ច្រកជាផ្លូវការ។



④ ដេរបិទការ៉ុងដោយប្រើម៉ាស៊ីនដេរ។ សសេរព័ត៌មានដោយប្រើហ្វឺត។



⑤ សមាជិកក្រុមទាំងអស់គឺត្រូវបានស្នើឲ្យទុកផលិតផលសម្រេចក្នុងឃ្លាំងពូជ។ ឃ្លាំងពូជត្រូវតែស្អាតជានិច្ចដើម្បីបញ្ចៀសនូវសត្វល្អិតផ្សេងៗ។





# 5-3 ពត្រៀមនៃស្តង់ដារគុណភាពពូជ

ស្តង់ដារគុណភាពពូជ(%)

| កត្តា | ទទួលស្គាល់ | អនុញ្ញាត |
|---|---|---|
| គ្រាប់ពូជសុទ្ធ (អប្បបរមា) | 98 | 98 |
| កំទេចកំទី (អតិបរមា) | 2 | 2 |
| គ្រាប់ស្មៅ (អតិបរមាន) | 0.05 | 0.1 |
| គ្រាប់ដំណាំផ្សេងៗ (អតិបរមា) | 0.1 | 0.2 |
| គ្រាប់ពូជស្រូវផ្សេងទៀត (អតិបរមា) | 0.1 | 0.2 |
| ដំណុះ (អប្បបរមា) | 85 | 85 |
| សំណើម (អតិបរមា) | 13 | 13 |
| អនុបាតគ្រាប់ពេញ | 95 | 95 |



# 5-4 ការធ្វើតេស្តិ៍ដំណុះ





① យកសំណាកគ្រាប់ពូជ ហើយត្រាំក្នុងទឹកឲ្យបាន២៤ម៉ោង។



② ដាក់ក្រដាសអនាម័យចូលក្នុងចានដំណុះ។



③ ដាក់គ្រាប់ស្រូវដែលបានត្រាំចូលក្នុងចានដំណុះឲ្យបាន១០០គ្រាប់ ដាក់ទឹកឲ្យសើមខ្លាំង។



④ រាប់ចំនួនគ្រាប់ដែលបានដុះបន្ទាប់បានរយៈពេល២ថ្ងៃ។



⑤ នេះជាគំរូនៃគ្រាប់ស្រូវដែលដុះ។

⑥ គណនាអត្រាដំណុះ

ឧទា.) នៅពេលចំនួនគ្រាប់ដែលបានដុះគឺ៩៥គ្រាប់ក្នុងចំណោម១០០គ្រាប់ដែលបានធ្វើតេស្តិ៍សាកដំណុះ។

៩៥/១០០ =0.៩៥

អត្រាដំណុះ = ៩៥%

# ឧបសម្ព័ន្ធ



## កំណត់ត្រាអធិការកិច្ចសំរាប់ផលិតកម្មគ្រាប់ពូជសុទ្ធអនុញ្ញាត

### អធិការកិច្ចលើទី១

__________________ ក្រុមផលិតពូជ

ឈ្មោះអ្នកផលិតៈ__________________________________

ID: ________________________________________________

ថ្ងៃទីៈ__________________________________________

ឈ្មោះអ្នកអធិការកិច្ចទី១ៈ _____________________________ ហត្ថលេខាៈ ______________

ឈ្មោះអ្នកអធិការកិច្ចទី២ៈ _____________________________ ហត្ថលេខាៈ ______________

| | | | |
|---|---|---|---|
| ប្រភពពូជ | គ្រាប់ពូជសុទ្ធទទួលស្គាល់ចំណាត់ថ្នាក់ខ្ពស់ | ជាប់ ☐ | ធ្លាក់ ☐ |
| ថ្នាលសំណាបនៅដាច់ដោយឡែក | ដោយរង | ជាប់ ☐ | ធ្លាក់ ☐ |
| ទីស្រែនៅដាច់ដោយឡែកពីពូជផ្សេងទៀត | យ៉ាងហោចណាស់៥ម.បើរំពឹងថាថ្ងៃចេញផ្កាដូចគ្នា | ជាប់ ☐ | ធ្លាក់ ☐ |
| លូតលាស់ស្មើរគ្នា | លើសពី៧០%ក្នុងមួយគុមព | ជាប់ ☐ | ធ្លាក់ ☐ |
| សត្វល្អិត និងជំងឺ | បំផ្លាញតិចតួច | ជាប់ ☐ | ធ្លាក់ ☐ |
| ពូជលាយ | តិចជា៣ដើមក្នុង១០០ម$^{២}$ | ជាប់ ☐ | ធ្លាក់ ☐ |
| ស្មៅ | អប្បរមា | ជាប់ ☐ | ធ្លាក់ ☐ |
| **វាយតម្លៃរួម** | | ជាប់ ☐ | ធ្លាក់ ☐ |

អនុសាសន៍ៈ____________________________________________________

## កំណត់ត្រាអធិការកិច្ចសំរាប់ផលិតកម្មគ្រាប់ពូជសុទ្ធអនុញ្ញាត

### អធិការកិច្ចលើទី២

__________________ ក្រុមផលិតពូជ

ឈ្មោះអ្នកផលិតៈ__________________________________

ID: ________________________________________________

ថ្ងៃទីៈ__________________________________________

ឈ្មោះអ្នកអធិការកិច្ចទី១ៈ _____________________________ ហត្ថលេខាៈ ______________

ឈ្មោះអ្នកអធិការកិច្ចទី២ៈ _____________________________ ហត្ថលេខាៈ ______________

| | | | |
|---|---|---|---|
| ការលូតលាស់ស្មើគ្នា | ច្រើនជាង៧០%នៃគុម្ពស្រូវ | ជាប់ ☐ | ធ្លាក់ ☐ |
| ចំនួនដើមសំណាប | ១ទៅ២ដើមក្នុងមួយគុម្ព | ជាប់ ☐ | ធ្លាក់ ☐ |
| ជំងឺបាកាណាក្នុងស្រែ | គ្មាន | ជាប់ ☐ | ធ្លាក់ ☐ |
| ជំងឺបាកាណាក្នុងស្រែកសិករជិតខាង | ៥ដើមក្នុង១០០ម$^{២}$រវាង៥ម. | ជាប់ ☐ | ធ្លាក់ ☐ |
| សត្វល្អិត និងជំងឺ | បំផ្លាញតិចតួចជា១០% | ជាប់ ☐ | ធ្លាក់ ☐ |
| ពូជលាយ | តិចជា៣ដើមក្នុង១០០ម$^{២}$ | ជាប់ ☐ | ធ្លាក់ ☐ |
| ស្មៅ | អប្បរមា | ជាប់ ☐ | ធ្លាក់ ☐ |
| **វាយតម្លៃរួម** | | ជាប់ ☐ | ធ្លាក់ ☐ |

អនុសាសន៍ៈ____________________________________________________

## កំណត់ត្រាអធិការកិច្ចសំរាប់ផលិតកម្មគ្រាប់ពូជសុទ្ធអនុញ្ញាត

### អធិការកិច្ចលើទី៣

__________________ ក្រុមផលិតពូជ

ឈ្មោះអ្នកផលិតៈ__________________________________

ID: _________________________________________________

ថ្ងៃទីៈ__________________________________________

ឈ្មោះអ្នកអធិការកិច្ចទី១ៈ _____________________________ ហត្ថលេខាៈ _______________

ឈ្មោះអ្នកអធិការកិច្ចទី២ៈ _____________________________ ហត្ថលេខាៈ _______________

| | | | |
|---|---|---|---|
| ទីស្រែនៅដាច់ដោយឡែកពីពូជផ្សេងទៀត | យ៉ាងហោចណាស់៥ម.បើរំពឹងថាថ្ងៃចេញផ្ការវាង៧ថ្ងៃ | ជាប់ ☐ | ធ្លាក់ ☐ |
| លូតលាស់ស្មើរគ្នា | លើសពី៧០%ក្នុងមួយគុមព | ជាប់ ☐ | ធ្លាក់ ☐ |
| សត្វល្អិត និងជំងឺ | បំផ្លាញតិចតួច១០% | ជាប់ ☐ | ធ្លាក់ ☐ |
| ពូជលាយ | តិចជា៣ដើមក្នុង១០០ម$^{២}$ | ជាប់ ☐ | ធ្លាក់ ☐ |
| ស្មៅ | អប្បរមា | ជាប់ ☐ | ធ្លាក់ ☐ |
| **វាយតម្លៃរួម** | | ជាប់ ☐ | ធ្លាក់ ☐ |

អនុសាសន៍ៈ____________________________________________________________

## កំណត់ត្រាអធិការកិច្ចសំរាប់ផលិតកម្មគ្រាប់ពូជសុទ្ធអនុញ្ញាត

### អធិការកិច្ចលើទី៤

__________________ ក្រុមផលិតពូជ

ឈ្មោះអ្នកផលិតៈ__________________________________

ID: _________________________________________________

ថ្ងៃទីៈ__________________________________________

ឈ្មោះអ្នកអធិការកិច្ចទី១ៈ _____________________________ ហត្ថលេខាៈ _______________

ឈ្មោះអ្នកអធិការកិច្ចទី២ៈ _____________________________ ហត្ថលេខាៈ _______________

| | | | |
|---|---|---|---|
| សត្វល្អិត និងជំងឺ | បំផ្លាញតិចតួចជា១០% | ជាប់ ☐ | ធ្លាក់ ☐ |
| ពូជលាយ | តិចជា៣ដើមក្នុង១០០ម$^{២}$ | ជាប់ ☐ | ធ្លាក់ ☐ |
| ស្មៅ | អប្បរមា | ជាប់ ☐ | ធ្លាក់ ☐ |
| **វាយតម្លៃរួម** | | ជាប់ ☐ | ធ្លាក់ ☐ |

អនុសាសន៍ៈ____________________________________________________________

# តារាងប្រភេទជំងឺ និងថ្នាំកំចាត់ជំងឺ

| ឈ្មោះជំងឺ | | | ថ្នាំគីមីអាចប្រើប្រាស់បាន | |
|---|---|---|---|---|
| Rice Blast |  | ជំងឺប្លាស់ | SAWANT 400EC, CARBENZIM 500FL, SANASA 100SC, TANAXA 700WP, Flash 75WP | សាវន្ត400EC, កាបេនស៊ីម500FL,<br>សាណាសា100SC, តាណាហ្សា700WP , ផ្លាស់75WP |
| (Bacterial) Leaf Blight |  | ជំងឺរលាកស្លឹកដែលបង្ក<br>ឡើងដោយបាក់តេរី | Not identified | ពុំទាន់បានកំណត់ |
| Sheath Blight |  | ជំងឺរលាកស្រទបស្លឹក | SAKATA 500SC, VALIDAN 5SL | សាកាតា500SC, វ៉ាលីដាន5SL |
| Rice Stripe(virus) |  | ជំងឺឆ្នូតស្រូវ (វីរុស) | There is no chemical to control virus directly. Control of Brawn Planthopper (virus transmitter) is the first step, and usable chemicals are as follows.<br>ACTION5SC NATO 55EC, SECSAIGON 25EC, OSIN 50WP | ពុំមានថ្នាំគីមីណាដើម្បីទប់ស្កាត់វីរុសដោយផ្ទាល់បានទេ។ ការទប់ស្កាត់មមាចត្នោត(ភ្នាក់ងារចម្លងវីរុស)គឺជាជំហានដំបូងបង្អស់ និងមានថ្នាំគីមីអាចប្រើប្រាស់បានដូចខាងក្រោមនេះ, អ៊ែកសិន5SC ណាតូ55EC,<br>សិកសៃហ្គន25EC, អូស៊ីន50WP |

# តារាងសត្វល្អិត និងថ្នាំកំចាត់សត្វល្អិត

| ឈ្មោះសត្វល្អិត | | ថ្នាំគីមីដែលអាចប្រើប្រាស់បាន | |
|---|---|---|---|
| (English) | (Khmer) | (English) | (Khmer) |
| Rice Army Worm  | ដង្កូវហ្វូង | NATO 55 EC, VITASI 480EC, ACTION5SC | ណាតូ55 EC, វីតាស៊ី480EC, អូស៊ីន5SC |
| Brawn Planthopper  | មមាចត្នោត | VITASI 480EC, CYRIPHOS 585EC, SECSAIGON10EC, ACTION5SC NATO 55EC, SECSAIGON 25EC, OSIN 50WP, VINO 200SC, NAFAZA 350SC | វីតាស៊ី480EC, ស៊ីរីផូស585EC, សិកសៃហ្គន10EC, អ៊ែកសិន5SC, ណាតូ55EC, សិកសៃហ្គន25EC, វីណូ200SC, ណាផាហ្សា350SC |
| Green Leafhopper   | មមាចខៀវ | VITASI 480EC, CYRIPHOS 585EC, OSIN 50WP, VIFONE 200SL, NAFAZA 350SC | វីតាស៊ី480EC, ស៊ីរីផូស585EC, អូស៊ីន50WP, វីហ្វូន200SL, ណាផាហ្សា350SC |
| Leaf holder   | ដង្កូវមូរស្លឹក | VICARE 36EC, ALPHAN 5 EC, VITASI 480EC, CYRIPHOS 585EC, SECSAIGON 10EC, SECSAIGON 25EC, CYPENRAN 10EC, DIAZAN 50EC, VINO 200SC, VIGO 500EC, PERAN 50EC, KINALUX 25EC | វីឃែរ36EC, អាល់ហ្វាន5EC, វីតាស៊ី480EC, ស៊ីរីផូស 585EC, សិកសៃហ្គន10EC, សិកសៃហ្គន25EC,ស៊ីប៉េរ៉ង់10EC, ឌីអាហ្សាន50EC, វីណូ200SC , វីហ្គោ500EC,ប៉េរ៉ង់50EC, គីណាលុច25EC, |
| Rice Bugs   | ស្រឹងស្រូវ | CYRIPHOS 585EC, SECSAIGON 10EC, SECSAIGON 25EC, OSIN 50WP, VINO 200SC, NAFAZA 350SC | ស៊ីរីផូស 585EC, សិកសៃហ្គន10EC, សិកសៃហ្គន25EC, អូស៊ីន50WP, វីណូ200SC, ណាផាហ្សា350SC |
| Rice Case Worm  | ដង្កូវបំពង់កាត់ស្លឹក | CYPENRAN 10EC, VITASI 480EC, VIGO 500EC, KINALUX 25EC | វីតាស៊ី480EC, ស៊ីប៉េរ៉ង់10EC, វីហ្គោ500EC, គីណាលុច25EC |
| Yellow Stem Borer  | ដង្កូវស៊ីរូងដើមពណ៌លឿង | NATO 55EC, GOLDEN DRAGON 585EC, CYRIPHOS 585EC, CYPENRAN 10EC, DIAZAN 50EC, DIAPHOS 10H, NETOXIN 18SL, PERAN 50EC | ណាតូ55EC, ហ្គោលដិនដ្រាហ្គន585EC, ស៊ីរីផូស585EC,ស៊ីប៉េរ៉ង់10EC,ឌីអាហ្សាន50EC,ឌីអាហ្សាន10H, ណេតូស៊ីន10H, ប៉េរ៉ង់50EC, ឌីអាហ្វូស10H, ណេតូស៊ីន18SL, ប៉េរ៉ង់50EC |
| Rice Thrips   | ទ្រីបស្រូវ | DIAZAN 50 EC, DIAPHOS 10 H | ឌីអាហ្សាន50EC, ឌីអាហ្វូស10H |

# ថ្នាំកំចាត់ស្មៅសំរាប់ដំណាំស្រូវដែលអាចរកបានក្នុងទីផ្សារកម្ពុជា

| | | | | | |
|---|---|---|---|---|---|
| |  |  |  |  |  |
| ឈ្មោះថ្នាំ | ណូមីនី/Nominee 10SC | បីសូណា/BISONA 100SC | អស់កង្វល់/NO WORRY 100SC | ស្រែអស់ស្មៅ/Sre ors Smao | បាយ័នស្មៅ/Bayon Smao |
| គីមីសកម្ម | បីស្ពីរីបាកសូដ្យូម/Bispyribac sodium | | | | |
| មុខសញ្ញាស្មៅ | ឯកវត្សស្មៅ(ស្មៅដែលបញ្ចប់វដ្តជីវិតរបស់ខ្លួនរយៈមួយឆ្នាំ រឺតិចជាង)/Annual Grasses, ស្មៅស្លឹកធំ/Broadleaf Weeds | | | | |
| ព័ត៌មាននៃការប្រើប្រាស់ | •ប្រភេទស្មៅដុះចេញពីដីហើយ/ Post-emergence Type.<br>•សន្ទូង/ពង្រោះសើមៈ ដំណាក់កាលស្មៅមានស្លឹក៣-៤សន្លឹក ឬ៧-១៥ថ្ងៃបន្ទាប់ពីស្ទូង/ព្រោះរួច។<br>•បង្ហូរទឹកចេញមុននិងបាញ់ដើម្បីឲ្យដល់មុខសញ្ញាស្មៅ។ បញ្ចូលទឹកដាក់ស្រែវិញបន្ទាប់ពីបាញ់បាន១-៣ថ្ងៃប្រយោជន៍ដើម្បីទប់ស្កាត់ស្មៅ។<br>•លាយថ្នាំ១០ម.ល ជាមួយទឹក១៦លីត្រ។<br>•អត្រាបាញ់(កំរិតទឹក)ៈ ១៦០លីត្រ -៣២០លីត្រក្នុងផ្ទៃដីមួយហិចតា។.<br>•បាញ់លើស្លឹកស្មៅ(មិនស្រូបពីឫសទេ)។ | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| |  | |  |  | |  |
| ឈ្មោះថ្នាំ | វ៉ែថកអូម៉ូន/Vitoxomone | | ពីអានឆ័រ/PYANCHOR 3EC | ស្មៅស្រូវប្រាំង/Smao Srov Prang | | អ៊ិចស្ពឺត/Xpert 70WP |
| គីមីសកម្ម | ប្រូម៉ានីល/ Propanil | 24D | ពីរីបិនហ្សូស៊ីម/Pyribenzoxim | ឃ្វីនក្លរិច/Quinclorac | ហ្វិណូសាប្រប-ប៉េ-អ៊ីទីល/ Fenoxaprop-P-ethyl | ពីរ៉ាហ្សូស៊ុលហ្វូរ៉ុន-អេទី/ Pyrazosulfuron-ethyl |
| មុខសញ្ញាស្មៅ | ឯកវត្សស្មៅ/ Annual Grasses, | ស្មៅស្លឹកធំ/Broadleaf Weeds | ស្មៅបែកក្បាល/ Barnyard Grass ស្មៅស្លឹកធំ/Broadleaf Weeds | ស្មៅទូទៅ/Grasses | ស្មៅ(ស្មៅវា)/ Grasses (Crabgrass) | ស្មៅទូទៅ, ស្មៅស្លឹកធំ Grasses, Broadleaf Weeds |
| ព័ត៌មាននៃការប្រើប្រាស់ | •ប្រភេទស្មៅដុះចេញ | 2.4-D ស្រូបពីស្លឹក ដើម និងឫសរបស់ស្មៅ។ | •ប្រភេទស្មៅដុះចេញ | | | |

# ព័ត៌មានទំនាក់ទំនងក្រុមកសិករផលិតពូជស្រូវដែលគាំទ្រដោយគម្រោង APPP/JICA

| ខេត្ត | ក្រុមកសិករផលិតពូជ | | ឈ្មោះ និងលេខទូរស័ព្ទទំនាក់ទំនង |
|---|---|---|---|
| បាត់ដំបង |  | ក្រុមកសិករសាមគ្គី "ផលិតពូជស្រូវ" ស្រុកបាណន់ | លោក ទង ស៊ីមន : 088-488-8523<br>លោក អ៊ិន សួន: 053-662-9696 |
| |  | ក្រុមកសិករសាមគ្គី "ផលិតពូជស្រូវ" ស្រុកមោងឫស្សី | លោក មូល ម៉ឺន : 089-359-995<br>លោ ហូ ប៉ែន : 053-631-1889<br>អ្នកស្រី ផើង រី : 092-875-673 |
| |  | ក្រុមកសិករសាមគ្គី "ផលិតពូជស្រូវ" ស្រុកបវេល | លោក ហ៊ុល ខ្លឹម : 012-675-589<br>លោក សឿន ប៊ុនធឿន : 012-402-381<br>លោក ស្រី កូវ: 092-954216 |
| ពោធិ៍សាត់ |  | ស្ថានីយ៍កសិកម្មទួលល្ពៅ នៃ មន្ទីរកសិកម្មខេត្ត | លោក ឡេង ចិន្តាមុនី :012-879-877<br>លោក ហ៊ៅ ចាន់ដារា: 012-635-409 |
| កំពង់ឆ្នាំង |  | ក្រុមកសិករភ្នំតូចសាមគ្គី "ផលិតពូជស្រូវ" | លោក មាស សឿន : 012-681-523<br>លោក ឃឹប បូ : 092-358-997<br>អ្នកស្រី កែ ខាន់ : 017-435-165 |



សមាជិកទាំងអស់អនុវត្តន៍តាមគោលការណ៍ណែនាំស្តីពីផលិតកម្មពូជដែលបានបង្រៀនដោយគម្រោងAPPP/JICA ហើយប្រើប្រាស់ពូជស្រូវដើមស្របច្បាប់ដែលផលិតដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា(CARDI)*. លោកអ្នកអាចទទំនាក់ទំនងទិញពូជមានគុណភាពល្អបាន។